CITY OF LONGBEACH PRESS RELEASE

សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១ ខែកក្កដាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ឥឡូវនេះទីក្រុងឡុងប៊ិចកំពុងទទួលយកពាក្យសុំសម្រាប់កម្មវិធីជំនួយជួលក្នុងគ្រាអាសន្នសម្រាប់អ្នកជួលដែលមានសិទ្ធិទទួលដែលបានរងគ្រោះដោយជំងឺ COVID-១៩។

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងបានប្រកាសនៅថ្ងៃនេះថាទម្រង់ពាក្យសុំនិងឯកសារគឺមានសម្រាប់កម្មវិធីជំនួយជួលដែលទើបនឹងបើកថ្មីដែលនឹងជួយផ្តល់ជំនួយសង្គ្រោះដល់អ្នកជួលដែលមានសិទ្ធិទទួលដែលបានរងគ្រោះដោយសារជំងឺរាតត្បាត COVID-១៩។ កម្មវិធីនេះបានអនុម័តជាឯកច្ឆន្ទកាលពីដើមខែនេះដោយក្រុមប្រឹក្សាក្រុង។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "កម្មវិធីនេះនឹងជួយផ្តល់នូវជំនួយដែលត្រូវការជាចាំបាច់ដល់អ្នកជួលនៅឡុងប៊ិចរាប់រយនាក់និងម្ចាស់ផ្ទះរបស់ពួកគាត់ខណៈដែលជំងឺរាតត្បាតនៅតែបន្តជះឥទ្ធិពលដល់ទីក្រុងរបស់យើង។ ការផ្តល់ការគាំទ្រដោយផ្ទាល់ដល់អ្នកដែលត្រូវការគឺចាំបាច់ដើម្បីធ្វើឱ្យសេដ្ឋកិច្ចរបស់យើងដំណើរការទៅមុខ។"

កម្មវិធី LB CARES ជំនួយនៃការជួលក្នុងគ្រាអាសន្ន (LB CARES) ដែលគ្រប់គ្រងដោយក្រសួងសេវាកម្មអភិវឌ្ឍន៍របស់ទីក្រុងនឹងផ្តល់ប្រាក់រហូតដល់ $1,000 ដុល្លារក្នុងមួយខែសម្រាប់ថ្លៃជួលដល់តែ ៣ ខែដល់អ្នកដែលរស់នៅទីក្រុងឡុងប៊ិចដែលមានសិទ្ធិទទួលបានដោយបានបាត់បង់ប្រាក់ចំណូល

ដោយសារ COVID-19 និងមានប្រាក់ចំណូលទាបដូចបានកំណត់ដោយតម្រូវការសហព័ន្ធ។ ការបង់ប្រាក់ជំនួយប្រចាំខែនឹងផ្តល់ជូនម្ចាស់ដីឬម្ចាស់ផ្ទះដោយផ្ទាល់ក្នុងនាមអ្នកជួលដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍តាមការចូលរួមក្នុងកម្មវិធី។ ប្រាក់ជំនួយនេះនិងអាចប្រើដើម្បីបង់ថ្លៃជួលដែលត្រូវទូទាត់ក្នុងកំឡុងពេលមានសិទ្ធិទទួលជំនួយគឺចាប់ពីថ្ងៃទី ២៧ ខែមីនាឆ្នាំ ២០២០ រហូតដល់ចុងបញ្ចប់នៃបទបញ្ជារក្សាសុវត្ថភាពដោយនៅផ្ទះរបស់ទីក្រុង។

នាយកក្រសួងសេវាកម្មអភិវឌ្ឍន៍លោក Oscar Orci បានមានប្រសាសន៍ថា "ការិយាលយ័លំនៅដ្ឋាន និងអ្នកជិតខាងរបស់យើងមានសេចក្តីរីករាយក្នុងការជួយដល់សហគមន៍របស់យើងតាមរយៈការផ្តល់ជំនួយនៃការជួលក្នុងកំឡុងពេលមានជំងឺរាតត្បាតនេះ។"

អ្នកដាក់ពាក្យសុំដែលមានសិទ្ធិទទួលបានត្រូវបញ្ជូនឯកសារបញ្ជាក់ពីការបាត់បង់ប្រាក់ចំណូលដែលបណ្តាលមកពីការបញ្ឈប់ការងារ កាលផ្អាកការងារមួយរយៈពេល ឬការកាត់បន្ថយនៃម៉ោងធ្វើការឬប្រាក់ខែក្នុងកំឡុងពេលជំងឺរាតត្បាត COVID-19 នេះចាប់ផ្តើមពីថ្ងៃទី ២៧ ខែមីនា។ រាល់ឯកសាររួមទាំងកិច្ចព្រមព្រៀងជួលនឹងត្រូវឆ្លងកាត់ការផ្ទៀងផ្ទាត់។

ឯកសារដាក់ពាក្យសុំនិងព័ត៌មាន (ជាភាសាអង់គ្លេស អេស្បាញ ខ្មែរ និងតាហ្គាល) ហើយផងដែរតម្រូវការសម្រប់សិទ្ធិទទួលបានគឺមាននៅលើគេហទំព័រនៃកម្មវិធីនេះនៅ៖ longbeach.gov/lbcares។

ព័ត៌មានលម្អិតអំពីកម្មវិធីគឺមានដូចខាងក្រោម៖

- អ្នកដែលចាប់អារម្មណ៍ចង់ដាក់ពាក្យអាចស្នើសុំឯកសារដាក់ពាក្យដែលអាចផ្ញើតាមប្រៃសណីយ៍ទៅដល់ផ្ទះដោយទូរស័ព្ទទៅលេខ 562.570.3000 ក្នុងម៉ោងធ្វើការឬផ្ញើអ៊ីមែលទៅ LBCares@longbeach.gov។
- អ្នកដែលមានចំណាប់អារម្មណ៍អាចមកទទួលយកឯកសារដាក់ពាក្យសុំដោយផ្ទាល់ចាប់ពីម៉ោង ៩ ព្រឹកដល់ ១១ ព្រឹកថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍នៅឯផ្លានៅកណ្តាលសាលាក្រុង (ដែលមានអាសយដ្ឋាន 411 W. Ocean Blvd.) តែប៉ុណ្ណោះ។
- ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកដាក់ពាក្យសុំក្នុងការពិនិត្យមើលតម្រូវការរបស់កម្មវិធីនិងដើម្បីប្រមូលឯកសារចាំបាច់កញ្ចប់ឯកសារដាក់ពាក្យសុំដែលបានបំពេញរួចដែលត្រូវផ្ញើមកតាម

ប្រៃសណីយ៍គឺនឹងត្រូវទទួលចាប់ពីថ្ងៃច័ន្ទទី ១៣ ខែកក្កដាដល់ថ្ងៃច័ន្ទទី ២៧ ខែកក្កដាឆ្នាំ ២០២០ តែប៉ុណ្ណោះ។

  - កញ្ចប់ឯកសារដាក់ពាក្យសុំត្រូវទៅដល់ការិយាល័យប្រៃសណីយហើយមានត្រាវាយលើសំបុតមិនលើសពីថ្ងៃទី ២៧ ខែកក្កដានិងផ្ញើទៅអាសយដ្ឋាន៖ Long Beach CARES Emergency Rental Assistance Program, 411 W. Ocean Blvd., 3rd Floor, Long Beach, CA 90802។

- កញ្ចប់ឯកសារដាក់ពាក្យសុំដែលបានបំពេញរួចក៏អាចយកទៅទម្លាក់ដោយផ្ទាល់នៅចន្លោះម៉ោង ៩ ព្រឹកដល់ ១១ ព្រឹកថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍នៅឯផ្លានៅកណ្តាលសាលាក្រុង (Long Beach City Hall Plaza) តែប៉ុណ្ណោះ។
  - កញ្ចប់ឯកសារដាក់ពាក្យសុំដែលបានយកមកទម្លាក់ដោយផ្ទាល់នឹងត្រូវទទួលចាប់ពីថ្ងៃអង្គារទី ១៤ ខែកក្កដាតរហូតដល់ថ្ងៃព្រហស្បតិ៍ទី ២៣ ខែកក្កដាឆ្នាំ ២០២០។
- នឹងមិនទទួលការដាក់ស្នើសុំតាមអ៊ីនធឺណិតទេ។
- រាល់ពាក្យសុំទាំងអស់នឹងត្រូវរក្សាទុកសម្រាប់ការចាប់ឆ្នោត។ ឯកសារស្នើសុំប្រមាណ ១៧០០ នឹងត្រូវជ្រើសរើសដោយការចាប់ឆ្នោតនៅខែសីហាឆ្នាំ ២០២០។
- បុគ្គលិកការិយាល័យក្រុងនឹងពិនិត្យនិងផ្ទៀងផ្ទាត់ឯកសារដាក់ពាក្យសុំដែលត្រូវបានចាប់ឆ្នោត។ ប្រសិនបើឯកសារដាក់ពាក្យដែលត្រូវបានចាប់ឆ្នោតមិនពេញលេញឬមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់គឺនឹងមានការចាប់ឆ្នោតបន្ថែមដើម្បីជំនួសរាល់ពាក្យសុំដែលមានការខ្វះខាត។
- អ្នកដែលបានដាក់ពាក្យសុំនឹងទទួលដំណឹងអំពីលទ្ធផលតាមប្រៃសណីយ៍យ៉ាងឆាប់រហ័ស។
- បុគ្គលិកការិយាល័យក្រុងនឹងទាក់ទងម្ចាស់ផ្ទះឬម្ចាស់ដីដើម្បីចាប់ផ្តើមរត់ការដោយមានការបំពេញទម្រង់បែបបទ IRS W-9 និងកិច្ចព្រមព្រៀងទទួលយកការបង់ថ្លៃដោយចូលរួមក្នុងកម្មវិធីនេះ។
- ប្រសិនបើមានការយល់ព្រមសន្លឹកសែកនឹងត្រូវផ្ញើដោយផ្ទាល់ទៅដល់ម្ចាស់ផ្ទះ / ម្ចាស់ដីក្នុងនាមអ្នកដាក់ពាក្យសុំ។ ការទូទាត់គឺរំពឹងថានឹងចេញនៅថ្ងៃទី ២៤ ខែសីហាឆ្នាំ ២០២០។

LB CARES ត្រូវបានផ្តល់មូលនិធិដោយទឹកប្រាក់ ៣ លានដុល្លារពីសហគមន៍អភិវឌ្ឍន៍មេរោគកូរ៉ូណា (CDBG-CV) និងទឹកប្រាក់ចំនួន ២ លានដុល្លារបន្ថែមពីកម្មវិធីភាពជាដៃគូវិនិយោគ HOME ដែលចំនួនមូលនិធិត្រូវបានទុកសម្រាប់កម្មវិធីនេះ។ លើសពីនេះទៀតការិយាល័យអ្នកត្រួតពិនិត្យនៃខោនធី Los Angeles លោកស្រី Janice Hahn បានបរិច្ចាគថវិកាចំនួន ៣០ ម៉ឺនដុល្លារសម្រាប់កម្មវិធីនេះ។

សម្រាប់ព័ត៌មានបន្ថែមឬដើម្បីសួរសំណួរអំពី LB CARES សូមទូរស័ព្ទមកលេខ 562.570.3000 ក្នុងម៉ោងធ្វើការឬផ្ញើអ៊ីមែលទៅ LBCares@longbeach.gov ។

ក្នុងកិច្ចខិតខំដែលពាក់ព័ន្ធក្រុមប្រឹក្សាក្រុងក៏កំពុងស្វែងរកជម្រើសជំនួយផ្សេងៗសម្រាប់ម្ចាស់អចលនៈទ្រព្យដែលបានរងផលប៉ះពាល់ដោយ COVID-១៩ រួមមានជំនួយលើការសងប្រាក់ពន្ធលើទ្រព្យសម្បត្តិ និងលទ្ធភាពនៃមូលនិធិប្រាក់កម្ចីវិល។ កាលពីខែឧសភាទីក្រុងឡុងប៊ិចបានយល់ព្រមពន្យារពេលបទប្បញ្ញត្តិគ្រាអាសន្នដែលបន្តការបញ្ឈប់ការបណ្តេញចេញនៃអ្នកជួលផ្ទះនិងអ្នកជួលកន្លែងពាណិជ្ជកម្មមួយចំនួន។

សូមចូលទៅមើលធនធានរបស់ទីក្រុងសម្រាប់ម្ចាស់ផ្ទះ អ្នកជួល និងម្ចាស់ដី។

សម្រាប់ព័ត៌មានថ្មីៗអំពីជម្ងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #